## បើសិនជាលោក-អ្នកត្រូវការជំនួយផ្នែកច្បាប់

លោក-អ្នកប្រហែលជាមានសិទ្ធិទទួលការជួយពី GBLS បើសិនជាលោក-អ្នករស់នៅក្នុងតំបន់ដែលយើងផ្តល់កិច្ចបំរើ ហើយប្រាក់ចំណូលរបស់លោក-អ្នកមិនលើសពី 125% នៃ កំរិតប្រាក់ចំណូលតាមច្បាប់រដ្ឋសំរាប់ជនក្រីក្រ។ (អតិថិជនចាស់ៗ មិនចាំបាច់គិតតាមកំរិតប្រាក់ចំណូលឡើយ។) យើងផ្តល់ជំនួយផ្លូវច្បាប់ដែលមានទាំងពីការផ្តល់ការណែនាំរហូតដល់ការពារពេញមុខអាស្រ័យតាមសេចក្តីត្រូវការ។ បុគ្គលិករបស់យើងត្រូវចែកជាអង្គភាពតាមបទពិសោធន៍ ផ្លូវច្បាប់ដើម្បីឲ្យត្រូវតាមបញ្ហាដែលអតិថិជនប្រឈមមុខ។

## ទាក់ទងយើង


ស្ថាប័នជំនួយផ្នែកច្បាប់នៃតំបន់បស់ស្តន
Greater Boston Legal Services
197 Friend Street
Boston, MA 02114
617.371.1234 ហ្វ៊ាក្ស: 617.371.1222
TDD: 617.371.1228

ស្ថាប័នជំនួយផ្នែកច្បាប់នៃតំបន់ខេមប្រិចនិងសាំមីវៀល
Cambridge and Somerville Legal Services
60 Gore Street, Suite 203
Cambridge, MA 02141
617.603.2700 ហ្វ៊ាក្ស: 617.494.8222
TDD: 617.494.1757

www.gbls.org


មានអ្នកបកប្រែសំរាប់អ្នកដែលមិននិយាយភាសាអង់គ្លេស

® GCIU 274C

## តំបន់ដែលក្រសួងជំនួយផ្នែកច្បាប់តំបន់បស់ស្តន់ផ្តល់កិច្ចបំរេ




GBLS ក៏ជួយដល់មនុស្សចាស់ៗនៅក្រុងផ្សេងៗ: Acton, Bedford, Boxborough, Burlington, Carlisle, Concord, Harvard, Lexington, Lincoln, Littleton, Maynard, North Reading, Reading, Stow, និង Wilmington.

GBLS អាចផ្តល់កិច្ចបំរើដល់អតិថិជនបានក៏សូមអរគុណ ចំពោះការឧបត្ថម្ភថវិកា ពីស្ថាប័នជំនួយខាងផ្លូវច្បាប់រដ្ឋម៉ាស្សាជូសេត្ស៍ យូណៃធិតវេនៃតំបន់មាត់សមុទ្ររដ្ឋម៉ាស្សាជូសេត្ស៍ ស្ថាប័នក្នុងតំបន់សំរាប់មនុស្សចាស់អង្គការមូលនិធិ ជាច្រើនទៀតគ្គសាជីវកម្ម ហើយនិង
បុគ្គលសប្បុរសជនដទៃទៀត និងក្រុមហ៊ុនការិយាល័យ
ច្បាប់ទូទាំងតំបន់នៃទីក្រុងបស់ស្តន់។

GBLS រីករាយនឹងទទួលនូវប្រាក់សប្បុរសជនដែលម្ចាស់ប្រាក់អាចអះអាងពេលបង់ពន្ធ។ សូមមេត្តាទាក់ទងយើង។

អង្គការជំនួយផ្នែកច្បាប)នៃតំបន)បស)ស្តន)មានមោទនភាពធ្វើជាដៃគូជាមួយ
អង្គការយូណៃធិតវេនៃតំបន)មាត)សមុទ្ររដ្ឋមាស្សាជូសេត្ស៍។

United Way of Massachusetts Bay

# Greater Boston Legal Services

...ហើយនិងយុត្តិធ៌មសំរាប)ទាំងអស)គ្នា



# ផ្តល់នូវការជួយផ្នែកច្បាប់ខាងបទប្រវេណី (មិនមែនបទឧក្រិដ្ឋ) ដោយឥតគិតថ្លៃដ៏មានប្រសិទ្ធភាពខ្ពស់ដល់ពលរដ្ឋក្រីក្រក្នុងតំបន់បស់ស្តុន

## ដំណើរការដើម្បីភាពយុត្តិធ៌ម

ជារៀងរាល់ថ្ងៃ មេធាវីនិងអ្នកជំនួយផ្នែកច្បាប់នៃ GBLS ផ្តល់យោបល់ផ្នែកច្បាប់និងធ្វើជាតំណាងយ៉ាងយកចិត្តទុកឲ្យបុគ្គលដែលមានប្រាក់ចំណូលតិចតួច។ លើសពីនោះទៅទៀត មនុស្សម្នានិងក្រុមគ្រួសារក្រីក្ររាប់ពាន់ នាក់ទៀត ទទួលផលប្រយោជន៍ពីប្រព័ន្ធគាំទ្ររបស់ GBLS ដែលធ្វើការឲ្យអតិថិជនរបស់គេ។ ឧទាហរណ៍ខ្លះៗរួមបញ្ចូលទាំង:

- បង្កើននូវសុវត្ថិភាពដល់ស្ត្រីនិងកូនៗដែលរងការវាយធ្វើបាប។ អរគុណដល់ច្បាប់ដែលកែប្រែល្អជាងមុនទាក់ទងទៅនឹងអាណាព្យាបាល, ការជួបសួរសុខទុក្ខ ហើយនិងបញ្ហាឲ្យនៅឲ្យឆ្ងាយ។
- ភាពប្រសើរឡើងចំពោះយានដំណើរសាធារណៈសំរាប់ មនុស្សរាប់ពាន់នាក់ ដែលពិការនោះជាលទ្ធផលនៃកិច្ចយល់ព្រមទៅនឹងបណ្តឹងជាក្រុមជាមួយនឹង អាជ្ញាធរដឹកជញ្ជូនសាធារណៈនៃរដ្ឋម៉ាស្សាជូសេត្ស៍កាលពីខែមេសាឆ្នាំ២០០៦ ដែលមាន GBLS ធ្វើជាតំណាងឲ្យក្រុមអ្នកដើមចោទ។
- ភាពប្រសើរឡើងនៃការការពារដល់ជនរងគ្រោះនយោបាយ និងការផ្តន់ទារទោសដោយសារជំនឿផ្លូវភេទដែលសុំសេចក្តីជ្រកកោននៅក្នុងសហរដ្ឋអាមេរិក។
- តម្លើងប្រាក់ម៉ោងដល់កម្មករប្រាក់ខែទាបដែលជាលទ្ធផលនៃច្បាប់ស្តីពីប្រាក់ខែរស់នៅក្នុងទីក្រុងបស់ស្តន់ហើយនិងការតម្លើងប្រាក់ខែដែលទាបបំផុតក្នុងរដ្ឋម៉ាស្សាជូសេត្ស៍។
- ធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធនិកម្មបទ(ការគ្មានការធ្វើ)សំរាប់កម្មករប្រាក់ចំណូលតិច អ្នកសុំប្រាក់ឥតការធ្វើដែលមិននិយាយភាសាអង់គ្លេស និងអ្នកដែលរួចផុតពីអំពើហិង្សា ហើយនិង
- ការរក្សាទុកឲ្យបានយូរអង្វែងនូវផ្ទះមានថ្លៃជួលថោកសំរាប់អ្នកក្រីក្រ មនុស្សចាស់ជរា ហើយនិងអ្នកពិការជិត៣០០០ ល្វែងដែលគេបំរុងនឹងប្តូរទៅជាផ្ទះជួលដែលមានតម្លៃថ្លៃ។

## សេចក្តីត្រូវការ

ទន្ទឹមនឹងកិច្ចការដ៏អស្ចារ្យទាំងប៉ុន្មានរបស GBLS វានៅមិនគ្រប់គ្រាន់ឡើយ។ ជារៀងរាល់ថ្ងៃ បីក្នុងចំណោមអតិថិជនប្រាំនាក់ដែលមានហេតុផលគ្រប់គ្រាន់ក្នុងការសុំ ត្រូវគេបដិសេធដោយមិនមានបុគ្គលិកផ្នែកជួយគាំទ្រគ្រប់ គ្រាន់។ អ្នកទាំងនេះ បើទោះជាមានហេតុផលគ្រប់គ្រាន់ តាមច្បាប់ក៏ដោយ ក៏មិនមានកន្លែងដទៃទៀតទៅដើម្បីរកយុត្តិធ៌មឡើយ។

## កិច្ចបំរើការ

GBLS ផ្តល់ការជួយផ្នែកច្បាប់យ៉ាងយកចិត្តទុកដាក់ចំពោះ បញ្ហាធ្ងន់ធ្ងរដែលក្រុមគ្រួសារក្រីក្រនិងបុគ្គលផ្សេងៗ រួមបញ្ចូលទាំងមនុស្សចាស់ជរានិងជនពិកា រផងប្រឈមមុខ។ កិច្ចបំរើការចំបងមាន:

**ភាពមានកិច្ចការធ្វើ——ការពារសិទ្ធិកម្មករប្រាក់ខែតិចតួច:** ជំនួយនៅពេលឥតការធ្វើ ការហ្វឹកហ្វឺនដើម្បីការងារ ប្រាក់ ខែ(រួមបញ្ចូលទាំងប្រាក់ឈ្នួលតិចបំផុតនិងប្រាក់លើសម៉ោង) គ្រួសារនិងការខកពីការងារដោយសារបញ្ហាសុខភាព បញ្ហាផ្សេងៗពីការបង់ពន្ធ ការឧទ្ធរណ៍របស់អ្នកជំនួយពេទ្យដែលមានសញ្ញាប័ត្រ និងការរើសអើងនៅកន្លែងធ្វើការ(មានកំរិតតាមកាលទេសៈ)។

**ច្បាប់គ្រួសារ-សុវត្ថិភាព សន្តិសុខ ភាពម្ចាស់ការផ្នែកថវិកា:** ការពារជនរងគ្រោះដាច់ មុខពីអំពើហិង្សា ដើម្បីធានាសុវត្ថិ ភាពរបស់ពួកគេនិងកូនៗ បញ្ហាពីអាណាព្យាបាល និងការទៅជួបសួរសុខទុក្ខ ប្រាក់ជួយឧបត្ថម្ភកូន ការលែងលះ និងការបញ្ជាក់ពីភាពជាឪពុក។

**សុខភាពនិងពិការភាព-ការសុំឲ្យគេជួយផ្នែកសុខភាពនិងពិការភាព:** ជួយសុំប្រាក់ជំនួយពីរដ្ឋាភិបាលសំរាប់ជនពិការ ជួយផ្នែកសុខភាព ការ ដឹកជញ្ជូនសាធារណៈ ប្រាក់ជំនួយពីសង្គមកិច្ចនៅពេលពិការ(SSDI) ចំណូលបន្ថែម(SSI) MassHealth និងកម្ម វិធីដើម្បីសុខភាពសាធារណៈដទៃទៀត។ កម្មវិធីពិសេសគាំទ្រផ្នែកថ្នាំសង្កូវ ទទួលខុសត្រូវសំណុំរឿងពាក់ព័ន្ធទៅនឹងប្រាក់ជំនួយខាងការព្យាបាលនិងជំនួយប្រហាក់ប្រហែលគ្នា។

**ផ្នែកផ្ទះសម្បែង-រក្សាផ្ទះសម្បែងតម្លៃសមរម្យសំរាប់អ្នកជួលមានប្រាក់ចំណូលតិចតួច:** ប្រមែលប្រមូលនិងរក្សាទីស្នាក់អាស្រ័យ សំរាប់គ្រួសារឥតទីជំរក ការពារអ្នកដែលគេឲ្យចុះចេញពីផ្ទះជួល ជួយរកផ្ទះដែលមានតម្លៃសមរម្យ រក្សានូវផ្ទះរដ្ឋដែលនៅមាននៅឡើយ ហើយនិងបង្កើនចំនួនផ្ទះដែល មានតម្លៃសមរម្យថ្មីៗថែមទៀត។

**ផ្នែកឥន្ទោប្រវេសន៍-ការពារសេរីភាព:** ការដាក់ពាក្យសុំសំរាប់អ្នកដែលគេចពីប្រទេសរបស់ខ្លួនដោយសារបញ្ហនយោបាយ ឬក៏ការផ្តន្ទាទោសដោយការនិយមភេទ ស្ត្រីឥន្ទោប្រវេសន៍ស្របច្បាប់រងទុក្ខទោសក្នុងសហរដ្ឋអាមេរិក និងអនិតិជនឥន្ទោប្រវេសន៍ដែលចង់បានឯករាជ្យភាពពីអ្នកល្មើសបំពាន ហើយនិងជំនួយក្នុងការដាក់ពាក្យសុំសំរាប់ក្រុមជនឥន្ទោប្រវេសន៍ដទៃទៀតដែលត្រូវគេទទួលមកសហរដ្ឋ អាមេរិកតាមច្បាប់ពិសេសសំរាប់ជនឥន្ទោប្រវេសន៍។

**ប្រាក់រដ្ឋចិញ្ចឹម-រក្សានូវសន្តិសុខផ្នែកប្រាក់គេឲ្យនិងជួយក្នុងអន្តរកាលដើម្បីរក ការធ្វើ:** ជួយសុំនិងរក្សានូវប្រាក់ជំនួយ បណ្តោះអាសន្នសំរាប់គ្រួសារតាមរយៈកូន ក្រោមអាយុ (TAFDC) ការមើលបីបាច់ក្មេង ប្រាក់ហូតស្តែម និងជំនួយបន្ទាន់ដល់មនុស្សចាស់ អ្នកពិការនិងក្មេងក្រោមអាយុ(EAEDC)។។ ជួយឲ្យមានការសិក្សានិងហ្វឹកហ្វឺន ហើយនិងកិច្ចបំរើទាក់ទងប្រាក់រដ្ឋជួយនិងការពារអ្នករួចផុតពីអំពើហិង្សានិងគ្រួសារដែលមានឪពុកម្តាយ ឬកូនដែលពិការ។

## កម្មវិធីពិសេស

GBLS មានកម្មវិធីពីរបីដើម្បីការពារយុត្តិធ៌មដល់បុគ្គលណាដែលប្រឈមមុខនឹងឧបសគ្គ។ មេធាវីនិងអ្នកជំនួយខាងច្បាប់របស់យើងនិយាយភាសាស្ពេន្នីស ហេសៀនក្រេអូល ប៉ទុយគ្គី ចិននិងវៀតណាម។ យើង ផ្តល់អ្នកបកប្រែចំពោះភាសាដទៃទៀតផងដែរ។ លើសពីនេះទៅទៀត GBLS បានបង្កើតនូវកម្មវិធីពិសេសផ្សេងៗ ដើម្បីផ្តល់ក្នុងការចុះផ្ទាល់និងជួយដល់ពលរដ្ឋក្រុមណាមួយពិតប្រាកដ។

**អង្គភាពចុះផ្ទាល់សំរាប់ជនជាតិអាស៊ី:** ផ្តល់នូវការចុះជួយផ្ទាល់ និងផ្នែកច្បាប់ ដល់ជនឥន្ទោប្រវេសន៍ជាតិអាស៊ីក្នុងបញ្ហាគ្រួសាររឿងឥន្ទោប្រវេសន៍ ការរកកិច្ចការធ្វើ ផ្ទះសម្បែង ហើយនិងច្បាប់ប្រាក់ជំនួយ។ ការពារកូនក្តីជាក្រុមនៅក្នុងសហគមន៍ ដើម្បីអប់រំឲ្យយល់ដឹងពីសិទ្ធិចំបងរបស់ជនឥន្ទោប្រវេសន៍ សិទ្ធិរបស់កម្មករ និងពីផ្ទះសម្បែងដែលមានថ្លៃជួលថោកៗ។

**កម្មវិធីច្បាប់នៅក្នុងសហគមន៍:** ធ្វើការជាមួយក្រុមនានាក្នុងសហគមន៍ តាមរយៈការប្រមូលផ្តុំការគាំទ្រ និងសកម្មភាពផ្លូវច្បាប់នៅក្នុងសហគមន៍ ដោយការប្រឹងប្រែងហ្មត់ចត់។ បុគ្គលិកកម្មវិធីជួយស្ថាបនាវិជ្ជាស្ថានប្រជាធិបតី ហើយនិងជួយអភិវឌ្ឍសហគមន៍ ដើម្បីមានឱកាសផ្នែកសេដ្ឋកិច្ចជួយពង្រឹង និងលើកកំពស់សហគមន៍នានាដែលមានថវិកាចំណូលទាប។ មុខសញ្ញាដែលផ្តោតការយកចិត្តទុកដាក់បច្ចុប្បន្ន មានការរក្សាចំនួនផ្ទះជួលដែលមានតម្លៃទាប ដីធ្លីសំរាប់សហគមន៍ប្រើប្រាស់ និងគំរោងច្បាប់។

**អង្គភាពច្បាប់សំរាប់មនុស្សចាស់:** ផ្តល់នូវការចុះផ្ទាល់និង ជំនួយផ្នែកច្បាប់ដល់មនុស្សចាស់អាយុ៦០ឆ្នាំឡើង តាមការជួយផ្នែក: សិទ្ធិពីការជួលផ្ទះនិងអ្នកជួយឲ្យគេបញ្ហាការបីបាច់នៅមន្ទីរមនុស្សជរា សូស្យាល់ ប្រាក់ហូតស្តែម អេសអេសអាយ មេដីខេត ការការពារខាងអាណាព្យាបាល និងអភិរក្សភាព ព្រមទាំងបញ្ហាអ្នកប្រើប្រាស់។

**សិទ្ធិពីសុខភាពផ្លូវចិត្តនិងពិការភាព:** ផ្តល់នូវការជួយផ្នែកច្បាប់ដល់មនុស្ស ចាស់និងក្មេងដែលពិការខាងផ្លូវចិត្ត ដូចជា ក្នុងការប្រកាន់រើសអើងសិទ្ធិដើម្បីទទួលការពារព្យាបាលផ្លូវ ចិត្តនិងកិច្ចបំរើផ្សេងទៀតក្នុងសហគមន៍ សិទ្ធិពីការរស់នៅ ក្នុងវិជ្ជាស្ថាន ហើយនិងការសិក្សាពិសេស។